00207751

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/I/66

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 07 / 2008
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ២៤ កក្កដា ២០០៨

សាធារណៈ

សេចក្តីសម្រេចដោយអនុលោមតាមមាត្រា ៣(១២) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនរូបដែលគ្មានមេធាវីតំណាង ចំពោះពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ខ្លួនក្នុងការថ្លែងប្រាប់ផ្ទាល់មាត់ជូនអង្គជំនុំជម្រះ

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យ៉ុង ផានិត

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. CHAMBRE PRELIMINAIRE

00207752

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

C22/I/66

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញមានឯកសារដូចខាងក្រោម ដែលភាគីដែលដាក់ឯកសារ បានសរសេរសម្គាល់ថា “សម្ងាត់”។

- សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីរូបដែលគ្មានមេធាវីតំណាង ចំពោះពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ខ្លួនក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ (“សេចក្តីសន្និដ្ឋានតប”) ដែលបានដាក់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨។

២. មាត្រា ៣(១២)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអវតក[១] ចែងថា:

“ការស៊ើបសួរត្រូវធ្វើឡើងជាសម្ងាត់។ ភាគីដែលដាក់ឯកសារអាចបង្ហាញពីសំណូមពររបស់ខ្លួនដើម្បីដាក់ឯកសារនោះជាអត្ថបទ“សាធារណៈ” “សម្ងាត់” ឬ “បិទស្លាកបោះត្រា” ទៅតាមករណីសមស្រប។ មានតែសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះប៉ុណ្ណោះ ដែលមានអំណាចពិនិត្យមើលឯកសារដើម្បីកំណត់ថា តើការកំណត់ប្រភេទអត្ថបទទាំងនោះមានលក្ខណៈសមរម្យដែរឬទេ។ សេចក្តីសម្រេចណាមួយស្តីពីបញ្ហានេះរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះត្រូវមានអានុភាពអនុវត្តក្នុងអំឡុងពេលនៃសវនាការបន្តបន្ទាប់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមានអំណាច តាមគំនិតផ្តួចផ្តើម ឬ តាមពាក្យសុំរបស់ភាគី ក្នុងការកែប្រែសេចក្តីសម្រេចនោះមួយផ្នែក ឬ ទាំងមូល ក្រោយពីបានជូនដំណឹងទៅភាគី ដែលអាចទទួលឥទ្ធិពលនៃសេចក្តីសម្រេចនោះ និង ផ្តល់ឱ្យភាគីនូវសិទ្ធិចូលរួមសវនាការ។

៣. អង្គបុរេជំនុំជម្រះបានពិនិត្យមើលឯកសារនេះឡើងវិញ ដើម្បីបញ្ជាក់ថាចំណារដែលសរសេរសម្គាល់ថា “សម្ងាត់” នេះធ្វើឡើងសមរម្យដែរឬទេ។

៤. អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណារថា “សម្ងាត់” នេះធ្វើឡើងសមរម្យ ក្នុងគោលបំណងការពារអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះនៅក្នុងឯកសារ។ ប៉ុន្តែ ដោយពិចារណាឃើញថាការដាក់ឯកសារទាំងអស់ដទៃទៀតចំពោះរឿងនេះ បានដាក់ជាសាធារណៈ និងដោយពិចារណាឃើញថាខ្លឹមសារឯកសារសំខាន់ទាំងមូលមិនមានអ្វីជាសម្ងាត់ វាជាការសមស្របក្នុងការដាក់ឯកសារដែលមានផ្នែកលុបចោល ជាសាធារណៈ។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

ឯកសារដែលមានផ្នែកលុបចោលនឹងត្រូវដាក់ជាឯកសារសាធារណៈ ដោយក្រឡាបញ្ជីអង្គបុរេជនុំជម្រះ។ 

ភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER ECCC CHAMBRE PRÉLIMINAIRE

**ប្រាក់ គឹមសាន**

---

[១] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វ០២ “ការដាក់ឯកសារនៅ អ.វ.ត.ក” ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨។